**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

# គោលការណ៍ណែនាំ

# សម្រាប់ការគាំទ្របន្តដល់ក្រុមកសិករសិក្សាខ្នាតតូច

**រៀបចំដោយៈ** នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម និងលេខាធិការដ្ឋានកម្មវិធី ASPIRE
**ឧបត្ថម្ភដោយៈ** កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

ខែ ឧសភា ឆ្នាំ ២០១៧

# មាតិកា

ទំព័រ

សេចក្តីផ្តើម......3
**១ .ការចុះសិក្សាតម្រូវការទីផ្សារ និងវិភាគ**......4
គោលបំណង:......4
លទ្ធផលរំពឹងទុក:......4
**២ការប្រជុំ និងពិភាក្សាជាមួយក្រុម ឬសហគមន៍ .**......6
**៣រៀបចំវេទិការវាងក្រុមផលិត និងអ្នកប្រមូលទិញ**......6
**៤ .គាំទ្រសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មបន្ថែម**......6
**៥រៀបចំកិច្ចសន្យា រវាងក្រុមផលិត និងអ្នកប្រមូលទិញ .**......7
**៦តាមដាន និងវាយតម្លៃ .**......8
**៧ តួនាទី .និងភារកិច្ចរបស់មន្ត្រីជំនាញ**......8
**៩ផែនការថវិកា .**......10

# សេចក្តីផ្តើម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានដាក់ចេញនូវគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជានាឆ្នាំ២០១៥ បានបង្ហាញថា ការផ្សព្វផ្សាយកសិកម្មត្រូវផ្លាស់ប្តូរយុទ្ធសាស្ត្រចេញពីការផ្សព្វផ្សាយដែលជម្រុញដោយផ្នែកផ្គត់ផ្គង់ ដើម្បីផលិតកម្មទៅរកការផ្សព្វផ្សាយដើម្បីតម្រូវការទីផ្សារ។ អនុលោមទៅតាមកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាលសេវា និងសកម្មភាពផ្សព្វផ្សាយកសិកម្មត្រូវធ្វើវិមជ្ឈការនៅថ្នាក់មូលដ្ឋាន ដោយពង្រឹងសមត្ថភាពមន្ត្រីនៅថ្នាក់ស្រុកនិងថ្នាក់ឃុំ ជាពិសេសលើការងារធ្វើផែនការ និងការសម្របសម្រួលខ្សែចង្វាក់តម្លៃកសិកម្ម។

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) បានចាប់ផ្តើមអនុវត្តពីពាក់កណ្តាលឆ្នាំ២០១៥ ដោយអនុវត្តទៅតាមគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា និងរួមចំណែកក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ កម្មវិធី ASPIRE អនុវត្តគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជាក្នុងខេត្តគោលដៅចំនួនប្រាំ រួមមាន៖ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ក្រចេះ និង ព្រះវិហារ នៅជំហានទី១ និងពង្រីកទៅខេត្តប្រាំផ្សេងទៀត ក្នុងឆ្នាំ ២០១៨ រួមមាន៖ ខេត្តកណ្តាល កំពត ព្រៃវែង ស្វាយរៀង និងខេត្តតាកែវ និងខេត្តផ្សេងទៀតចំនួនបី នៅជំហានទី២ ។

**កម្មវិធី** ASPIRE **មានគោលបំណង៖** កាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់របស់កសិករខ្នាតតូចក្រីក្រ និងងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា ។

**សមិទ្ធផលទី៣៖** កសិករសិក្សាខ្នាតតូចយ៉ាងហោចណាស់ចំនួន ១២០,000 គ្រួសារ លើកកម្ពស់ការងារធុរកិច្ចកសិកម្មរបស់ខ្លួន ប្រកបដោយភាពធន់ តាមរយៈការផ្តល់សេវាកម្មផ្សព្វផ្សាយកសិកម្ម និងការវិនិយោគរបស់កម្មវិធីលើហេដ្ឋារចនាសម្ព័ន្ធដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

**សូចនាករ៖** កសិករខ្នាតតូចយ៉ាងតិច ៩0,000 គ្រួសារ ដែលប្រកបអាជីវកម្មកសិកម្ម បានកើនប្រាក់ចំណេញដោយឆ្លងកាត់ការអនុវត្តបច្ចេកទេសថ្មីដែលបានសិក្សានិងចូលរួមក្នុងសកម្មភាពផ្សព្វផ្សាយកសិកម្មកម្មវិធីASPIR។

ដើម្បីសម្រេចបាននូវគោលបំណង និងសមិទ្ធផលខាងលើកម្មវិធី ASPIRE បានរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់គាំទ្រកសិករគោលដៅឲ្យមានការលើកកម្ពស់ការងារធុរកិច្ចកសិកម្មរបស់ខ្លួនប្រកបដោយភាពធន់ តាមរយៈការផ្តល់សេវាកម្មផ្សព្វផ្សាយកសិកម្មនិងការជួយស្វែងរកទីផ្សារដោយអនុវត្តទៅតាមជំហានដូចខាងក្រោម៖

១. ការចុះសិក្សាតម្រូវការទីផ្សារ និងវិភាគ
២. ការប្រជុំ និងពិភាក្សាជាមួយក្រុម ឬសហគមន៍
៣. រៀបចំវេទិការវាងក្រុមផលិត និងអ្នកប្រមូលទិញ

៤.គាំទ្រសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មបន្ថែម
៥. រៀបចំកិច្ចសន្យារវាងអ្នកផលិត និងឈ្មួញ
៦. តាមដាន និងវាយតម្លៃ
៧. តួនាទី និងភារកិច្ចរបស់មន្ត្រីបច្ចេកទេស
៨. ផែនការថវិកា។

## ១. ការចុះសិក្សាតម្រូវការទីផ្សារ និងវិភាគ

**គោលបំណង:**

- សិក្សាតម្រូវការផលិតផលកសិកម្ម (កសិផល) ផ្សេងៗនៅទីផ្សារ ក្នុងតំបន់ (ឃុំ ស្រុក...)
- យល់ដឹងពីផលលំបាក និងការប្រកួតប្រជែង ក្នុងការជម្រុញផលិតផលក្នុងស្រុក ទៅកាន់ទីផ្សារក្នុងតំបន់
- កំណត់ប្រភេទផលិតកម្ម/អាជីវកម្មកសិកម្ម សម្រាប់ផ្គត់ផ្គង់ទីផ្សារ
- កំណត់អ្នកប្រមូលទិញដើម្បីធ្វើជាដៃគូជាមួយក្រុមឬសហគមន៍ សម្រាប់ទីផ្សារ។

**លទ្ធផលរំពឹងទុក:**

- មន្ត្រីនិងបុគ្គលិកពាក់ព័ន្ធបានយល់អំពីនីតិវិធីឬវិធីសាស្ត្រនៃការសិក្សាទីផ្សារ ប្រមូលទិន្នន័យ
- ទិន្នន័យត្រូវបានវិភាគនិងកំណត់ផលិតផលដែលមានសក្តានុពលសម្រាប់តម្រូវការទីផ្សារ
- កំណត់បាននូវដៃគូផ្គត់ផ្គង់ ឬអ្នកប្រមូលទិញចូលរួមដំណើរការទីផ្សារ។

ការចុះសិក្សា៖ ឃុំ ស្រុក ...គោលដៅដែលមានសក្តានុពលសម្រាប់ផលិត និងផ្គត់ផ្គង់ទីផ្សារ។

**សង្ខេបពីដំណើរការសិក្សាតម្រូវការទីផ្សារ**



## ១.១. ផ្សព្វផ្សាយគោលការណ៍ណែនាំដល់មន្ត្រីបង្គោល

**គោលបំណង:** ផ្សព្វផ្សាយគោលការណែនាំដល់មន្ត្រីជំនាញឲ្យមានចំណេះដឹងសម្រាប់ការជួយគាំទ្រក្រុមកសិករសិក្សាខ្នាតតូច ឬសហគមន៍ដែលមានសក្តានុពលសម្រាប់ផលិតដល់ទីផ្សារ។

**លទ្ធផលរំពឹងទុក:** មន្ត្រីជំនាញមានចំណេះដឹងពី ដំណើរការ និងវិធីសាស្ត្រគាំទ្រក្រុមកសិករសិក្សាខ្នាតតូច។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងនាយកដ្ឋានផែនការនិងស្ថិតិ/ការិយាល័យទីផ្សារកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកចូលរួមទទួលខុសត្រូវក្នុងការដឹកនាំដំណើរការទាំងមូល និងចូលរួមបណ្តុះបណ្តាលដល់ដល់មន្ត្រីឬបុគ្គលិកជំនាញនៃមន្ទីរកសិកម្ម មន្ត្រីតាមដាននិងវាយតម្លៃ និងទីប្រឹក្សា M&E/MIS (ឧបសម្ព័ន្ធទី១)។

## ១.២. ផ្សព្វផ្សាយគោលការណ៍ដល់ភ្នាក់ងារអនុវត្ត (ស្រុក ឃុំ)

**គោលបំណង:** ណែនាំការប្រមូលទិន្នន័យ បញ្ចូលទិន្នន័យ នៃដំណើរការសិក្សាតម្រូវការទីផ្សារ និងបច្ចេកទេសគាំទ្រក្រុមកសិករ។

**លទ្ធផលរំពឹងទុក:** មន្ត្រីជំនាញថ្នាក់ស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ បានយល់និងមានទំនុកចិត្តក្នុងការអនុវត្តន៍ដំណើរការគាំទ្រក្រុមកសិករខ្នាតតូច និងការជម្រុញសហគមន៍ និងក្រុមផលិតក្នុងការផ្គត់ផ្គង់កសិផលដល់ទីផ្សារ។

មន្ត្រីជំនាញទីផ្សាររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកទទួលខុសត្រូវក្នុងការដឹកនាំបន្តការងារផ្សព្វផ្សាយគោលការណ៍និងវិធីសាស្ត្រ ដល់មន្ត្រីបច្ចេកទេសកសិកម្មស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ (ឧបសម្ព័ន្ធទី១)។

## ១.៣. វិធីសាស្ត្រ និងការប្រមូលទិន្នន័យលើទីផ្សារ

ការសិក្សា ទៅលើទីផ្សារក្នុងឃុំ ស្រុក គោលដៅ (ទីផ្សារដែលមានសក្តានុពលសម្រាប់កសិករគោលដៅ) ដែលកម្មវិធី ASPIRE បានគាំទ្រសេវាផ្សព្វផ្សាយបច្ចេកទេសដល់ក្រុមកសិករសិក្សាខ្នាតតូច។

- **ការប្រមូលទិន្នន័យ (ការសម្ភាសន៍) ៖** ក្នុងស្រុកនីមួយៗ មន្ត្រីកសិកម្មថ្នាក់ស្រុក និងភ្នាក់ងារផ្សព្វផ្សាយឃុំ ជាអ្នក កំណត់ផ្សារ និងអ្នកដែលត្រូវសម្ភាសន៍ និងចុះសម្ភាសន៍តាមទីផ្សារសំខាន់ៗ និងការបញ្ចូលទិន្នន័យ។
- **កំណត់សំណាក:** សម្ភាសន៍ជាមួយអ្នកលក់សំខាន់ៗ (អចិន្ត្រៃយ៍) ក្នុងទីផ្សារ និងឈ្មួញកណ្តាល
- កំណត់យកប្រភេទផលិតផលកសិកម្មជាអាទិភាពក្នុងការផ្គត់ផ្គង់ប្រចាំថ្ងៃ
- បញ្ចូលនិងបូកសរុបទិន្នន័យ រួមទាំងវិភាគនិងកំណត់ផលិតផលសម្រាប់តម្រូវការទីផ្សារ ដោយមានការជួយគាំទ្រពីមន្ត្រីជំនាញថ្នាក់ជាតិនិងថ្នាក់ខេត្ត។